ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៣៣៦ សហវ.ប

# សេចក្តីណែនាំ
# ស្តីពី
## នីតិវិធី និងបែបបទនៃការពិនិត្យ វាយតម្លៃលក្ខណសម្បត្តិផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារ ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងថារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ របស់មន្ត្រីរាជការនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរួមចំណែកកសាង និងអភិវឌ្ឍប្រទេស ស្របតាមទំហំស្នាដៃរបស់បុគ្គលម្នាក់ៗ និងដោយគោរពតាមខ្លឹមសារព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបែបបទ ស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា និង ប្រកាសលេខ ១០៨ សហវ.ប្រកប ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស និង មេដាយការងារ ក្រសួងសូមធ្វើការណែនាំដល់គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទ អំពីនីតិវិធី និងបែបបទ នៃការពិនិត្យ និងវាយតម្លៃ ផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារ ដូចខាងក្រោម ៖

**១-** គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង ត្រូវបង្កើតឱ្យមានគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលត្រូវរៀបចំ និងមានសមាសភាពដូចខាងក្រោម ៖

**ក- អគ្គនាយកដ្ឋាន** សមាសភាព រួមមាន:

| | |
|---|---|
| - អគ្គនាយក | ប្រធាន |
| - អគ្គនាយករង | សមាជិក |
| - ប្រធាននាយកដ្ឋានទទួលបន្ទុកការងារបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |

នាយកដ្ឋាន និងសាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាន ត្រូវរៀបចំគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលមានសមាសភាពដូចបានកំណត់ក្នុងចំណុច **ខ** និង **គ** ខាងក្រោម ។ បញ្ជីឈ្មោះបេក្ខជនរបស់នាយកដ្ឋាន និងសាខា/អង្គភាព ត្រូវបញ្ជូនមកនាយកដ្ឋានទទួលបន្ទុកកិច្ចការបុគ្គលិក របស់អគ្គនាយកដ្ឋានដើម្បីបូកសរុប និងធ្វើរបាយការណ៍ដាក់ជូនគណៈកម្មការអគ្គនាយកដ្ឋានពិនិត្យ និងសម្រេច មុននឹងបញ្ជូនមកនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ខ- នាយកដ្ឋាន:** សមាសភាព រួមមាន:

| | |
|---|---|
| - ប្រធាននាយកដ្ឋាន | ប្រធាន |
| - អនុប្រធាននាយកដ្ឋាន | សមាជិក |
| - ប្រធានការិយាល័យ | សមាជិក |

**គ- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /សាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាននៅរាជធានី-ខេត្ត**

សមាសភាព រួមមាន:

| | |
|---|---|
| - ប្រធានមន្ទីរ/សាខា/អង្គភាព | ប្រធាន |
| - អនុប្រធានមន្ទីរ/សាខា/អង្គភាព | សមាជិក |
| - ប្រធានការិយាល័យ/ទីស្នាក់ការ | សមាជិក |

២- ការវាយតម្លៃបេក្ខជន ត្រូវផ្អែកលើលក្ខណសម្បត្តិដូចខាងក្រោម៖

- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និង សកម្មភាពផ្ទុយពីច្បាប់រដ្ឋ
- គំនិតផ្តួចផ្តើម និង មនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាមច្នៃប្រឌិត និងទទួលខុសត្រូវខ្ពស់
- ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធភាព
- ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់អង្គភាពក្រសួង
- សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជនទូទៅ ។

៣- គណៈកម្មការខាងលើ មានភារកិច្ចប្រជុំពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិមន្ត្រីរាជការក្រោមឱវាទសម្រាប់ជ្រើសរើសជាបេក្ខជន ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ទៅតាមប្រភេទ និងវិស័យការងារ ស្របតាមខ្លឹមសារដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមលំដាប់នៃគ្រឿងឥស្សរិយយស និងមេដាយការងារ ដែលធ្លាប់បានទទួលកន្លងមកក្នុងក្របខ័ណ្ឌការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវកំណត់មិនឱ្យលើស ១០% នៃចំនួនក្របខ័ណ្ឌសរុបរបស់អង្គភាពនីមួយៗ និងឆ្លាស់វេនគ្នារយៈពេល ២ ឆ្នាំម្តង ។

គណៈកម្មការ អាចធ្វើការពិនិត្យវាយតម្លៃ និងលើកសំណើ ជាករណីពិសេស ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ផ្តល់ជូនដល់មន្ត្រីរាជការដែលមានស្នាដៃឆ្នើមលេចធ្លោ មន្ត្រីទទួលមរណភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈក្នុងបេសកកម្មការងារ និងមន្ត្រីដែលមានស្នាដៃការងារជាច្រើនឆ្នាំហើយត្រូវដល់អាយុចូលនិវត្តន៍ ។

៤- អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជន មកនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ កក្កដា នៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការនិមួយៗ ។

៥- នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការបូកសរុប និងធ្វើរបាយការណ៍ជាក់ជូនគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវស្នើគ្រឿងឥស្សរិយយស និងមេដាយការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ សីហា នៃឆ្នាំនីមួយៗ ដើម្បីពិនិត្យ និងសម្រេច ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមថា គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ សំដៅរក្សាបាននូវសុក្រឹតភាព និង តម្លៃនៃគ្រឿងឥស្សរិយយស និងមេដាយការងាររបស់ជាតិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន:</u>**

-ឯកឧត្តមរដ្ឋលេខាធិការ / អនុរដ្ឋលេខាធិការ
-ឯកឧត្តមអគ្គលេខាធិការ / អគ្គលេខាធិការរង
« ដើម្បីជូនជ្រាប »
-គ្រប់អគ្គនាយកដ្ឋាន ព្រមទាំងសាខាគយ និងរដ្ឋាករ សាខាពន្ធដារ រតនាគាររាជធានី ខេត្ត នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាព ក្រោមឱវាទក្រសួង
« ដើម្បីផ្សព្វផ្សាយ និងអនុវត្ត »
- ឯកសារ-កាលប្បវត្តិ